**សេចក្តីប្រកាសព័ត៌មាន**

០៤/២២/២០២០

ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច ៥៦២.៥៧០.NEWS (៦៣៩៧) jic@longbeach.gov
ប្រជាពលរដ្ឋសូមទូរស័ព្ទទៅលេខ ៥៦២.៥៧០.INFO (៤៦៣៦)

សម្រាប់សេចក្តីប្រកាសបន្ទាន់

# បណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិចភ្ជាប់គ្រួសារជាមួយនឹងធនធាននៅលើបណ្តាញអ៊ិនធឺរណែតតាមរយៈគេហទំព័រថ្មីរបស់បណ្ណាល័យ



ទីក្រុងឡុងប៊ិចរដ្ឋកាលីហ្វ័រញ៉ា - អ្នករស់នៅទីក្រុងឡុងប៊ិចអាចស្វែងរកសេវាកម្មឥតគិតថ្លៃរួមមានការកម្សាន្តការរៀនសូត្រតាមបណ្តាញអ៊ិនធរណេតនិងធនធានសម្រាប់អ្នកស្វែងរកការងារតាមរយៈគេហទំព័រថ្មីរបស់បណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិចដែលហៅថា បណ្ណាល័យរបស់អ្នកតាមផ្ទះ។ គេហទំព័រនេះត្រូវបានរចនាឡើងដើម្បីជាកន្លែងតែមួយនៃធនធានសម្រាប់សាធារណៈជនខណៈទីតាំងបណ្ណាល័យត្រូវបានបិទហើយបទបញ្ជារក្សាសុវត្ថិភាពដោយនៅផ្ទះត្រូវបានអនុវត្ត។

អភិបាលក្រុងលោករ៉ូប៊ឺតហ្គាសៀស(Robert Garcia)មានប្រសាសន៍ថា "គេហទំព័របណ្ណាល័យរបស់អ្នកតាមផ្ទះថ្មីនេះធ្វើឱ្យកាន់តែងាយស្រួលសម្រាប់គ្រួសារនៅឡុងប៊ិចក្នុងការបន្តចូលប្រើធនធាននៃបណ្ណាល័យរបស់យើងជា

ច្រើនក្នុងកំឡុងពេលដែលត្រូវនៅឆ្ងាយពីគ្នានេះដែលមិនធ្លាប់មានពីមុនមក។ គេហទំព័រនេះគឺជាធនធានដ៏ប្រសើរមួយដែលធានាថាគ្រប់គ្នាអាចចូលប្រើសេវាកម្មនៃបណ្ណាល័យរបស់យើងបាន។”

ប្រជាពលរដ្ឋនៃទីក្រុងឡុងប៊ិចអាចទទួលបានប័ណ្ណបណ្ណាល័យសាធារណៈនៃឡុងប៊ិច (LBPL) យ៉ាងងាយស្រួលទោះបីបណ្ណាល័យត្រូវបានបិទក៏ដោយ។ សូមចុះឈ្មោះតាមបណ្ដាញអ៊ីនធឺណិត។ បន្ទាប់មកទូរស័ព្ទទៅលេខ ៥៦២.៥៧០.៧៥០០ ដើម្បីភ្ជាប់ជាមួយនឹងបុគ្គលិកបណ្ណាល័យដែលនឹងជួយត្រៀមកាតដើម្បីឱ្យប្រើប្រាស់បាន។

លេខកាតបណ្ណាល័យនិងលេខអត្តសញ្ញាណផ្ទាល់ខ្លួននឹងបើកទ្វារទៅធនធានជាច្រើនសម្រាប់ក្រុមគ្រួសារទាំងមូលរួមមាន៖

- វគ្គសិក្សាហ្គេល(Gale Courses)ដែលផ្តល់នូវវគ្គសិក្សាកម្រិតមហាវិទ្យាល័យផ្នែកអភិវឌ្ឍជំនាញវិជ្ជាជីវៈនិងវគ្គបណ្តុះបណ្តាលផ្ទាល់ខ្លួន
- Brainfuse HelpNow ដែលជាសេវាកម្មដែលភ្ជាប់សិស្សផ្ទាល់នឹងគ្រូបង្រៀនគួតាមរយៈបណ្តាញអ៊ិនធរណេតដើម្បីទទួលជំនួយធ្វើលំហាត់
- Mango Languages ដែលជាការរៀនភាសាតាមបណ្តាញអ៊ិនធរណេតដែលរួមមានថ្នាក់អង់គ្លេសជាភាសាទី ២ (ESL) និង ៧០ ភាសាផ្សេងទៀតក្រៅពីភាសាអង់គ្លេស
- មជ្ឈមណ្ឌលព្រាងក្នុងការធ្វើតេស្តនិងការអប់រំ(Testing and Education Reference Center)ដែលជាកន្លែងដែលបុគ្គលអាចហាត់ធ្វើការប្រឡងចូលសាកលវិទ្យាល័យដូចជាតេស្ត SAT និង AP ឬហាត់ធ្វើការប្រឡងចូលសញ្ជាតិអាមេរិក
- សៀវភៅអូឌីយ៉ូសម្រាប់ស្តាប់និងសៀវភៅអេឡិចត្រូនិចសម្រាប់អាន

លោកស្រី Glenda Williams នាយកបណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិចបានមានប្រសាសន៍ថា "បេសកកម្មរបស់បណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិចគឺបំពេញតម្រូវការព័ត៌មានរបស់មនុស្សគ្រប់គ្នានៅក្នុងទីក្រុងរបស់យើង។ នៅក្នុងពេលវេលាជាប្រវត្តិសាស្ត្រនេះយើងខ្ញុំកំពុងប្រឹងប្រែងជាងពេលណាទាំងអស់ដើម្បីធ្វើឱ្យប្រាកដថាពលរដ្ឋទាំងអស់អាចទទួលបានសៀវភៅនិងព័ត៌មានតាមបណ្តាញអ៊ិនធរណេតដោយឥតគិតថ្លៃតាមរយៈគេហទំព័របណ្ណាល័យរបស់អ្នកតាមផ្ទះ”។

បណ្ណាល័យនេះក៏មានរៀបចំការនិទានរឿងលើបណ្តាញអ៊ិនធរណេតតាមរយៈ[ទំព័រហ្វេសប៊ុក(Facebook)]និង[ប៉ុស្តិ៍យូធូប(YouTube)]ផងដែរ។

សូមទូរស័ព្ទទៅបណ្ណាល័យសាធារណៈនៃឡុងប៊ិចនៅលេខ ៥៦២.៥៧០.៧៥០០ ចាប់ពីម៉ោង ១០ ព្រឹកដល់ម៉ោង ៥ ល្ងាចពីថ្ងៃអង្គារដល់ថ្ងៃសៅរ៍ប្រសិនបើលោកអ្នកមានសំណួរទាក់ទងនឹងបណ្ណាល័យឬសម្រាប់ព័ត៌មានបន្ថែម។

សម្រាប់ព័ត៌មានថ្មីៗស្តីអំពីជំងឺកូវីដ-១៩និងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងប្រតិបត្តិដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមចូលទៅកាន់គេហទំព័រ៖ longbeach.gov/COVID19 និងតាមដាន @LongBeachCity នៅលើហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #